00485615

ឯកសារដើម / CERTIFIED COPY/COPIE CERTIFIEE CONFORME

ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 03 / 2010

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ/No: D357/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 03 / 2010
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខ ៖ 002/19-09-2007-អ.វ.ត.ក.-ក.ស.ច.ស.

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០

ភាសា៖ ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងបទចោទស្តីពីការវាយប្រហារទៅលើវប្បធម៌

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា
ខៀវ សំផន
អៀង សារី
កាំង ហ្កេកអ៊ាវ ហៅ ឌុច
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ីន សុវន
ជេត វណ្ណលី
ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Laure DESFORGES
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Christine MARTINEAU

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សុវាន Jacques VERGÈS
ការ សាវុត្ថ François ROUX
Marie-Paule CANIZARÈS

00485616



**យើង យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនផ្សេងទៀត** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា២០៩ មាត្រា២១០ មាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ ដល់មាត្រា៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

បានឃើញវិធាន៣១ វិធាន៥៥ វិធាន៦៦ និងវិធាន៦៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធានផ្ទៃក្នុង”)

បានឃើញសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទចោទស្តីពីការវាយប្រហារទៅលើវប្បធម៌ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ (D357 “សំណើ”)។

## ឧព្វហេតុរបស់ភាគី

១. នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើរបស់ខ្លួនសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ ឲ្យបានពេញលេញទៅលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ ទាក់ទិនទៅនឹងការវាយប្រហារមកលើវប្បធម៌។ ស្នើសុំឲ្យតែងតាំងអ្នកជំនាញមួយរូបផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។ ស្នើសុំឲ្យស្តាប់ចម្លើយបុគ្គលដែលត្រូវបានបញ្ជាក់ឈ្មោះចំនួនប្រាំពីរនាក់ឡើងវិញ និងស្នើសុំឲ្យកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយបុគ្គលផ្សេងៗទៀតដែលមិនត្រូវបានបញ្ជាក់ឲ្យបានជាក់លាក់[1]។

---

[1] D357 ទំព័រ ១៧។

00485617



## សំអាងហេតុដីកាសម្រេច

២. ទាក់ទិនទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការវាយប្រហារមកលើវប្បធម៌ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំដៅទៅលើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ហើយជាពិសេសសំដៅទៅលើការបំផ្លិចបំផ្លាញអគារវប្បធម៌ ដូចជា វត្តអារាម[2]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលទាក់ទិនទៅនឹងការចោទប្រកាន់នានាស្តីពីសមាជិក នៃប្រជាជនចាម ក៏មានការចោទប្រកាន់នានាអំពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ភាសា និងវប្បធម៌ផងដែរ[3]។ សហចៅក្រមស៊ើបអង្កេតក៏បានទទួលអង្គហេតុ ទាក់ទិនទៅនឹងការបំបែកគ្រួសារ[4] និងអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ[5]។

៣. ទាក់ទិនទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងសំណើ ដូចជាពិធីស្តីដណ្តឹង[6] ពិធីមរណៈភាព និងសម្រាលកូន[7] ការស្រមៃ[8] ស្មារតីរបស់មនុស្ស[9] អត្តសញ្ញាណទីកន្លែង និងពេលវេលា[10] និងការប្រើប្រាស់ភាសា ដូចដែលបានរៀបរាប់នៅក្នុងសំណើ[11] សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សហព្រះរាជអាជ្ញាមិនបានបញ្ជូនអង្គហេតុទាំងនេះមកឲ្យសហចៅស៊ើបអង្កេតនៅឡើយទេ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានទទួលការប្តឹងអំពីបញ្ហាទាំងនេះឡើយ ហើយអនុលោមតាមវិធានផ្ទៃក្នុង៥៣(៣) សហចៅក្រមស៊ើបអង្កេតមិនអាចបំពេញកិច្ចស៊ើប

---

[2] សូមមើល ឧទាហរណ៍ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ១២, ៧០, ៧២។

[3] D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម។

[4] សូមមើល ឧទាហរណ៍ D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម កថាខណ្ឌ ៤, ៩, ១០ និង ១៥។ និង D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤១, ៦៩។

[5] D268/2 ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ កថាខណ្ឌ ៨។

[6] D357 កថាខណ្ឌ ១៤។

[7] D357 កថាខណ្ឌ ២១-២៦។

[8] D357 កថាខណ្ឌ ២៧-៣០។

[9] D357 កថាខណ្ឌ ២៧-៣០។

[10] D357 កថាខណ្ឌ ៣១-៣៣។

[11] D357 កថាខណ្ឌ ២៨, ២៩។

សួរទៅលើអង្គហេតុថ្មីណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញាបានទេ។

៤. ទាក់ទិនទៅនឹងសំណើសុំតែងតាំងអ្នកជំនាញមួយរូប អនុលោមតាមវិធានផ្ទៃក្នុង៣១(១) ដើម្បីធ្វើការស្រាវជ្រាវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀតពាក់ព័ន្ធនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងវប្បធម៌ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថាអនុលោមតាមវិធានផ្ទៃក្នុង៦៧(២) របស់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឲ្យ ធ្វើសេចក្តីព្រាងដីកាដំណោះស្រាយដោយបញ្ជាក់អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស។ នេះគឺជាការសន្មតជាមុនអំពីការពិនិត្យអង្គហេតុ នៅក្នុងសំណុំរឿង និងការវាយតម្លៃ អំពីបទចោទអ្វីខ្លះដែលអាច ឬមិនអាចត្រូវបានកំណត់។ សហចៅក្រមស៊ើបអង្កេតយល់ឃើញ ថា ចរិតលក្ខណៈនៃសំណើជាន់គ្នាជាសំខាន់ទៅលើតួនាទីរបស់សហចៅក្រមស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងវិធាន៦៧(២)។ ដូច្នេះ នៅក្នុងការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតនឹងពិចារណាទៅលើអង្គហេតុណាដែលខ្លួនត្រូវបានប្តឹង និងបានបំពេញកិច្ចស៊ើបសួរទាក់ទិនទៅនឹងការវាយប្រហារ ដែលអាចមានទៅលើវប្បធម៌ ហើយ ដោយផ្អែកទៅលើអង្គហេតុដែលខ្លួនរកឃើញ សហចៅក្រមស៊ើបអង្កេតអាចពិចារណាផងដែរ ទៅលើការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងបរិបទនេះ។

៥. ទាក់ទិនទៅនឹងសំណើសុំឲ្យស្តាប់ចម្លើយឡើងវិញបុគ្គលចំនួនប្រាំពីរនាក់ដែលបានផ្តល់ជូននោះសំណើនោះមិនបានចង្អុលបង្ហាញថាចម្លើយរបស់សាក្សី ដែលធ្វើឡើងដោយបុគ្គលនីមួយៗដែលបានបញ្ជាក់ឈ្មោះទាំងនោះមិនបានឆ្លើយតបឲ្យបានគ្រប់គ្រាន់យ៉ាងដូចម្តេចខ្លះ ទៅនឹងបញ្ហាផ្នែកច្បាប់ និងភស្តុតាង ដែលជាកម្មវត្ថុនៃសំណើនោះឡើយ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ថាមិនមានហេតុផលណាមួយ ក្នុងការស្តាប់ចម្លើយបុគ្គលដែលមានឈ្មោះនៅក្នុងសំណើនោះឡើងវិញឡើយ។

៦. លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សំណើនេះមានគោលបំណងបញ្ជូននូវបញ្ជីដែលមានលក្ខណៈមិនលម្អិតមួយ។ ជាគោលការណ៍ គ្រប់សំណើត្រូវតម្រូវឲ្យមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន។ ទោះបីជាភាគីអាចស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរជាបណ្តាញមួយ ឬស្នើសុំស្តាប់ចម្លើយក្រុមនៃបុគ្គលដែលអាចជាសាក្សីដែលមិនត្រូវបានកំណត់ជាក់លាក់ក៏ដោយ ក៏ត្រូវតែមានចំនុចគ្រប់គ្រាន់ តាមរយៈការបញ្ជាក់លម្អិតនៅក្នុងសំណើ ឬក៏យោងទៅលើឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ដើម្បីសម្រួលដល់ការបំពេញកិច្ចស៊ើបសួរ

00485619



បន្ថែមណាមួយដែលអាចកើតមាន។ ជាពិសេសនេះគឺជាស្ថានភាពសំដៅទៅរកការបញ្ចប់កិច្ចស៊ើបសួរ នៅពេលដែលសហចៅក្រមស៊ើបអង្កេតកំពុងតែឈានទៅដល់កម្រិតនៃភាពគ្រប់គ្រាន់ដែលបង្ហាញថា ការចំណាយធនធានបន្ថែមរបស់តុលាការនៅក្នុងការស៊ើបអង្កេតបន្ថែមមិនស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌ទេ។ តាមពិត សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើកាលពីលើកមុនៗសុំឱ្យបំពេញកិច្ចស៊ើបសួរចំពោះភាពមិនច្បាស់លាស់ នៅពេលដែលមិនមានសេចក្ដីលម្អិតគ្រប់គ្រាន់អំពីអត្តសញ្ញាណសាក្សីដែលបានត្រូវបានស្នើឡើង[12]។ ដោយយោងលើហេតុផលទាំងនេះ សហចៅក្រមស៊ើបអង្កេតបដិសេធសំណើដែលមិនបានបញ្ជាក់ឱ្យចំៗ ក្នុងការបំពេញកិច្ចស៊ើបសួរលើសពីបុគ្គលចំនួនប្រាំពីរនាក់ ដែលមានឈ្មោះនៅក្នុងសំណើ។

**ហេតុដូច្នេះសម្រេច:**

- **បដិសេធ** សំណើសុំតែងតាំងអ្នកជំនាញមួយរូប
- **បដិសេធ** សំណើសុំឱ្យស្ដាប់ចម្លើយបុគ្គលដែលត្រូវបានបញ្ជាក់ឈ្មោះចំនួនប្រាំពីរនាក់ឡើងវិញ និងស្នើសុំឱ្យកំណត់អត្តសញ្ញាណ និងស្ដាប់ចម្លើយបុគ្គលផ្សេងៗទៀតដែល មិនត្រូវបានបញ្ជាក់ឱ្យបានជាក់លាក់
- **បញ្ជាក់ថា** កម្មវត្ថុនៃសំណើត្រូវបានគ្របដណ្ដប់រួចហើយក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរក្នុងវិសាលភាពដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹង ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិវប្បធម៌ក្រោមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរបន្ថែម និង
- **កត់សម្គាល់ថា** ការកំណត់ប្រភេទបទល្មើសដ៏ត្រឹមត្រូវ នឹងត្រូវបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដោយផ្អែកទៅលើការវាយតម្លៃភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**Marcel LEMONDE** យូ ប៊ុនឡេង

[12] សូមមើល ឧទាហរណ៍ D300 ដីកាសម្រេចលើសំណើ D153, D172, D173, D174, D178 & D284 កថាខណ្ឌ ២២។